**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...០១...អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការបន្ថែមបៀវត្សមូលដ្ឋានជូនមន្ត្រីរាជការស៊ីវិល ការបង្កើនប្រាក់អាហារប្រចាំថ្ងៃ ជូនយោធិន នគរបាលជាតិ និង មន្ត្រីពន្ធនាគារ និង ការផ្ដល់ប្រាក់កម្រៃបន្ថែមជូនគ្រូបង្រៀនជាប់កិច្ចសន្យា

p

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្ដីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១១៣/១២០ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលឋានន្តរស័ក្តិ ថ្នាក់ សន្ទស្សន៍បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងាររបស់ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ និងភ្នាក់ងារបច្ចេកទេសរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៨៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការកែសម្រួលប្រាក់បៀវត្សមូលដ្ឋានរបស់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលប្រាក់បៀវត្សមូលដ្ឋានរបស់មន្ត្រីនគរបាលជាតិ
- បានឃើញអនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាននិងការបង្កើនបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការ
- បានឃើញអនុក្រឹត្យលេខ ៤៦៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីការបង្កើនបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃក្របខ័ណ្ឌ ឃ ក្របខ័ណ្ឌ គ ឋានន្តរស័ក្តិទី៣ និងក្របខ័ណ្ឌ គ ឋានន្តរស័ក្តិទី២ ក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

p

**សម្រេច**

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅបន្ថែមបៀវត្សមូលដ្ឋានជូនមន្ត្រីរាជការស៊ីវិលស្ថិតក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា បង្កើនប្រាក់អាហារប្រចាំថ្ងៃជូនយោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីពន្ធនាគារ និងផ្តល់ប្រាក់កម្រៃបន្ថែមជូនគ្រូបង្រៀនជាប់កិច្ចសន្យានៃក្រសួងអប់រំ យុវជន និងកីឡា។

អនុក្រឹត្យនេះ មិនមានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ តុលាការ មន្ត្រីរាជការបម្រើការងារក្នុងស្ថាប័នប្រឆាំងអំពើពុករលួយ និងអាជ្ញាធរសវនកម្មជាតិ។

**មាត្រា ២.-**

ត្រូវបានបង្កើនបៀវត្សមូលដ្ឋានប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលតាមចំនួនកំណត់ដូចខាងក្រោម÷

- ៤០០០០(បួនម៉ឺន)រៀល ក្នុងមួយខែដល់មន្ត្រីរាជការនៃក្របខ័ណ្ឌប្រភេទ ក ស្ថិតក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ៨០០០០(ប្រាំបីម៉ឺន)រៀល ក្នុងមួយខែដល់មន្ត្រីរាជការនៃក្របខ័ណ្ឌប្រភេទ ខ ប្រភេទ គ និងប្រភេទ ឃ ស្ថិតក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។



www.pheakdeylaw.com

**មាត្រា ៣.-**

ត្រូវបានបង្កើនប្រាក់អាហារប្រចាំថ្ងៃដែលជាផ្នែកនៃបៀវត្ស ជូនយោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីពន្ធនាគារ ឱ្យដល់ចំនួន ៤២០០(បួនពាន់ពីររយ) រៀល សម្រាប់ម្នាក់ក្នុងមួយថ្ងៃ។

**មាត្រា ៤.-**

ត្រូវបានផ្តល់ប្រាក់កម្រៃបន្ថែមចំនួន ៤០០០០(បួនម៉ឺន)រៀល ក្នុងមួយខែលើប្រាក់កម្រៃកិច្ចសន្យាប្រចាំខែ សម្រាប់គ្រូបង្រៀនចូលនិវត្តន៍ដែលត្រូវបានជ្រើសរើសឱ្យបំពេញការងារជាគ្រូបង្រៀនជាប់កិច្ចសន្យាចំណោះទូទៅ និងអគ្គរកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៥.-**

ការបន្ថែមបៀវត្សមូលដ្ឋាន ការបង្កើនប្រាក់អាហារប្រចាំថ្ងៃ និង ការផ្តល់ប្រាក់កម្រៃបន្ថែម ដូចមានចែង ក្នុងមាត្រា២ មាត្រា៣ និង មាត្រា៤ ខាងលើ ត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ តទៅ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com